ខួបគម្រប់ ៧០ ឆ្នាំ

សេចក្តីប្រកាស
ជាសកល
ស្តីពីសិទ្ធិមនុស្ស

#STANDUP4HUMANRIGHTS

# សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (UDHR) គឺជាឯកសារសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រសិទ្ធិមនុស្ស។ សេចក្ដីព្រាងនៃសេចក្ដីប្រកាសនេះ ត្រូវបានរៀបចំឡើងដោយតំណាងផ្សេងៗមកពីផ្នែកច្បាប់ និងវប្បធម៌ខុសៗគ្នា មកពីគ្រប់តំបន់នៃពិភពលោក សេចក្ដីប្រកាសនេះ ត្រូវបានប្រកាសដោយ មហាសន្និបាត អ.ស.ប នៅទីក្រុងប៉ារីស នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨ (សេចក្ដីសម្រេចលេខ ២១៧ A) ថាជាបទដ្ឋានរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឲ្យបានសម្រេច។ សេចក្ដីប្រកាសនេះកំណត់ជាលើកដំបូងនូវសិទ្ធិមនុស្សជាមូលដ្ឋានដែលត្រូវបានការពារជាសកល ហើយវាត្រូវបានបកប្រែជាង ៥០០ ភាសា។

UNITED NATIONS
**HUMAN RIGHTS**
OFFICE OF THE HIGH COMMISSIONER
*Cambodia*


@OHCHRCambodia
@OHCHR_Cambodia
UNCOHCHR
www.cambodia.ohchr.org
cambodia@ohchr.org

# បុព្វកថា

ដោយយល់ឃើញថា ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់សមាជិកគ្រប់រូប នៃគ្រួសារមនុស្ស ហើយនិងការទទួលស្គាល់សិទ្ធិស្មើភាពគ្នានិងសិទ្ធិដែលមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន ថាជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក។

ដោយយល់ឃើញថា ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំទៅកាន់អំពើព្រៃផ្សៃ សាហាវយង់ឃ្នង ធ្វើឱ្យក្តៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ និងដោយយល់ឃើញថា ការករកើតឡើងនូវពិភពលោកមួយ ដែលមនុស្សជាតិត្រូវមានសេរីភាពក្នុងការនិយាយស្តី និងជំនឿ និងការរួចចាកផុតពីភាពភ័យខ្លាច និងទុក៌តភាព ត្រូវបានប្រកាសថា ជាសេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ។

ដោយយល់ឃើញថា ជាការចាំបាច់ បើមិនចង់ឲ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ ធ្វើការបះបោរប្រឆាំងនឹងអំណាចផ្តាច់ការ និងការគាបសង្កត់ទេនោះ សិទ្ធិមនុស្សត្រូវតែបានការពារដោយនីតិរដ្ឋ។

ដោយយល់ឃើញថា ជាការចាំបាច់ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិនានា។

ដោយយល់ឃើញថា ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិ នូវជំនឿរបស់ខ្លួន

លើសិទ្ធិមូលដ្ឋានរបស់មនុស្ស លើសេចក្តីថ្លៃថ្នូរលើតម្លៃរបស់មនុស្ស និងលើសមភាពនៃសិទ្ធិរវាងបុរសនិងស្ត្រី ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅកាន់តែប្រសើរឡើងព្រមទាំងសេរីភាពកាន់តែទូលំទូលាយថែមទៀត។

ដោយយល់ឃើញថា ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋសមាជិកទាំងអស់សន្យាធានាលើកកំពស់ការគោរពសិទ្ធិជាសកល និងសេរីភាពមូលដ្ឋានឱ្យបានសម្រេច។

ដោយយល់ឃើញថា ការយល់ដឹងរួមមួយស្តីអំពីសិទ្ធិនិងសេរីភាពទាំងនេះ គឺមានសារៈសំខាន់បំផុត ដើម្បីបំពេញបានទាំងស្រុងនូវការសន្យាខាងលើនេះ។

## អាស្រ័យហេតុនេះ មហាសន្និបាតប្រកាសថា៖

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេសនិងប្រជាជាតិទាំងអស់ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួននូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះតាមរយៈការបង្រៀន និងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តជាសកលជាក់ស្តែងនូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិនិងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ទាំងក្នុងចំណោមប្រជាពលរដ្ឋ នៃរដ្ឋសមាជិក ទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដីដែលស្ថិតនៅក្រោមអំណាចនៃរដ្ឋទាំងនោះផង។

 ១ សេរីភាព និងសមភាព

 ២ សេរីភាពរួចផុតពីការរើសអើង

 ៣ សិទ្ធិរស់រានមានជីវិត

 ៤ សេរីភាពរួចផុតពីទាសភាព

 ៥ សេរីភាពរួចផុតពីទារុណកម្ម

 ៦ សិទ្ធិទទួលស្គាល់ចំពោះមុខច្បាប់

 ៧ សិទ្ធិស្មើភាពចំពោះមុខច្បាប់

 ៨ សិទ្ធិទទួលបានយុត្តិធម៌

 ៩ សេរីភាពរួចផុតពីការឃុំខ្លួនដោយបំពាន

 ១០ សិទ្ធិទទួលបានការជំនំជម្រះប្រកបដោយយុត្តិធម៌

១១ ការសន្មត់ជាមុនថាគ្មានទោស

១២ សិទ្ធិឯកជន

១៣ សេរីភាពដើរហើរ

១៤ សិទ្ធិជ្រកកោន

១៥ សិទ្ធិទទួលបានសញ្ជាតិ

១៦ សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ

១៧ សិទ្ធិជាម្ចាស់កម្មសិទ្ធិ

១៨ សេរីភាពខាងសាសនា ឬជំនឿ

១៩ សេរីភាពនៃការសម្ដែងមតិ

២០ សេរីភាពជួបប្រជុំ


២១ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ


២២ សិទ្ធិទទួលបានសន្តិសុខសង្គម


២៣ សិទ្ធិការងារ


២៤ សិទ្ធិសម្រាក និងលំហែកំសាន្ត


២៥ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់


២៦ សិទ្ធិទទួលបានការអប់រំ


២៧ សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ សិល្បៈ និងវិទ្យាសាស្ត្រ


២៨ សិទ្ធិទទួលបានពិភពលោកមួយសេរី និងយុត្តិធម៌


២៩ ភារកិច្ចចំពោះសហគមន៍របស់អ្នក


៣០ សិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបាន



# សេរីភាព និងសមភាព

មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាព ក្នុងផ្នែកសេចក្ដីថ្លៃថ្នូរ និងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកក្នុងស្មារតីភាតរភាពជាបងប្អូន។

**១**

**មាត្រា**



# សេរីភាពរួចផុតពីការរើសអើង

មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះដោយគ្មានការប្រកាន់បែងចែកបែបណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។ លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងយុត្តាធិការ ឬខាងអន្តរជាតិរបស់ប្រទេស ឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយនៃអធិបតេយ្យភាពក្តី។

២

មាត្រា



# ៣
មាត្រា

## សិទ្ធិរស់រានមានជីវិត

បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។



# សេរីភាពរួចផុតពីទាសភាព

**៤**

**មាត្រា**

គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និងទាសពាណិជ្ជកម្មត្រូវហាមឃាត់ ទោះតាមទម្រង់ណាក៏ដោយ។



# សេរីភាពរួចផុតពីទារុណកម្ម

គ្មានជនណាម្នាក់ ត្រូវទទួលរងការធ្វើទារុណកម្ម ប្រព្រឹត្តកម្មមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។

**៥**
**មាត្រា**



# ៦ មាត្រា

## សិទ្ធិទទួលស្គាល់ចំពោះមុខច្បាប់

មនុស្សម្នាក់ៗ មានសិទ្ធិឱ្យទទួលស្គាល់ពីបុគ្គលិកលក្ខណៈគតិយុត្តរបស់ខ្លួន នៅគ្រប់ទីកន្លែង។



# សិទ្ធិស្មើភាពចំពោះមុខច្បាប់

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។ មនុស្សគ្រប់រូប មានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង។

## ៧ មាត្រា

**៨**

**មាត្រា**



# សិទ្ធិទទួលបានយុត្តិធម៌

មនុស្សគ្រប់រូប មានសិទ្ធិទទួលបានដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព នៅចំពោះមុខសាលាក្តីជាតិ ដែលមានសមត្ថកិច្ច ចំពោះអំពើរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួន ដែលសិទ្ធិទាំងនោះត្រូវបាន ទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់។



# សេរីភាពរួចផុតពីការឃុំខ្លួន ដោយបំពាន

គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួន ដោយបំពានឡើយ។

៩ មាត្រា



# សិទ្ធិទទួលបានការជំនំជម្រះ ប្រកបដោយយុត្តិធម៌

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ ក្នុងការស្នើសុំឱ្យតុលាការឯករាជ្យ និងមិនលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ក្នុងការសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ច និងអំពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌមកលើខ្លួន។

**១០**
**មាត្រា**



# ការសន្មត់ជាមុនថាគ្មានទោស

១. ជនណាម្នាក់ដែលជាប់ចោទពីបទព្រហ្មទណ្ឌមានសិទ្ធិត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញតាមផ្លូវច្បាប់ នៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាគ្រប់យ៉ាងចាំបាច់សំរាប់ការការពារខ្លួន។

២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ដោយសារតែការប្រព្រឹត្ត ឬការភ្លាំងភ្លាត់ ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ក្នុងច្បាប់ជាតិ ឬអន្តរជាតិ នៅពេលដែលអំពើនោះ ត្រូវបានប្រព្រឹត្ត។ មិនត្រូវផ្តន្ទាទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្តក្នុងអំឡុងពេលបទល្មើសនោះបានកើតឡើងឡើយ។

**១១**

**មាត្រា**



១២
មាត្រា

# សិទ្ធិឯកជន

គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់ទាំងនេះ។

# ១៣
# មាត្រា



## សេរីភាពដើរហើរ

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរី និងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងព្រំដែននៃរដ្ឋនីមួយៗ។

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ។



# សិទ្ធិជ្រកកោន

១. មនុស្សគ្រប់រូប មានសិទ្ធិស្វែងរក និងទទួលកន្លែង ជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ពីបទល្មើសនៃនីតិរូម (មិនមែនជារឿងនយោបាយ) ឬពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និងគោលការណ៍ទាំងឡាយរបស់អង្គការសហប្រជាជាតិ។

១៤
មាត្រា



# សិទ្ធិទទួលបានសញ្ជាតិ

១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ។

២. គ្មានជនណាម្នាក់អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន ដោយបំពានបានឡើយ។

១៥
មាត្រា



១៦
មាត្រា

# សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងបង្កើតគ្រួសារ

១.បុរស និងស្ត្រី ដែលពេញវ័យ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារដោយមិនប្រកាន់ ឬកម្រិតលើ ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ។ បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍ និងក្នុងពេលរំលាយអាពាហ៍ពិពាហ៍។

២.អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន លុះត្រា តែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតសហព័ទ្ធទាំងពីរ (ប្ដីប្រពន្ធ)។

៣.គ្រួសារជាធាតុធម្មជាតិ និងជាធាតុមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ។



# សិទ្ធិជាម្ចាស់កម្មសិទ្ធិ

១. មនុស្សគ្រប់រូប ទោះជាបុគ្គលក្តី សមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។

២. គ្មានជនណាម្នាក់ត្រូវបានដកហូត កម្មសិទ្ធិដោយបំពានឡើយ។

១៧
មាត្រា



១៨
មាត្រា

# សេរីភាពខាងសាសនា ឬ ជំនឿ

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬ ជារួមជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តជាទម្លាប់ ការគោរពបូជា ព្រមទាំងតាមការប្រារព្ធពិធីសក្ការៈផ្សេងៗ។



# សេរីភាពនៃការសម្តែងមតិ

មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។ សិទ្ធិនេះ រាប់ទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយបញ្ចេញមតិបែបណាមួយក៏ដោយ។

## ១៩
## មាត្រា



# សេរីភាពជួបប្រជុំ

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ។

២០

មាត្រា



# សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ

១. មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។

២. មនុស្សគ្រប់រូប មានសិទ្ធិប្រើប្រាស់ដោយស្មើភាពនូវសេវាសាធារណៈក្នុងប្រទេសរបស់ខ្លួន។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ គឺជាមូលដ្ឋានអំណាចរបស់រដ្ឋាភិបាល។ ឆន្ទៈនេះ ត្រូវបានសម្តែងចេញតាមរយៈការបោះឆ្នោតទៀងទាត់ តាមពេលវេលាកំណត់ និងពិតប្រាកដ ដែលជាការបោះឆ្នោតមួយមានលក្ខណៈសកល ស្មើភាព ហើយការបោះឆ្នោតនេះទៀតសោត ត្រូវធ្វើដោយសម្ងាត់ ឬតាមនីតិវិធីការបោះឆ្នោតដោយសេរី និងសមមូល។

២១
មាត្រា



# សិទ្ធិទទួលបានសន្តិសុខសង្គម

មនុស្សគ្រប់រូប ក្នុងឋានៈជាសមាជិកមួយរូបនៃសង្គម មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិក្នុងការសម្រេច បានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់មិនអាចអត់បាន សម្រាប់សេចក្ដីថ្លៃថ្នូរ និងវឌ្ឍនកម្មដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្របតាមការរៀបចំ និងតាមធនធានរបស់ប្រទេសនីមួយៗ។

**២២**

**មាត្រា**

**២៣**

**មាត្រា**



# សិទ្ធិការងារ

១.មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងល័ក្ខខ័ណ្ឌត្រឹមត្រូវ និងពេញចិត្ត ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

២.មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។

៣.អ្នកធ្វើការងារ មានសិទ្ធិទទួលបានលាភសក្ការៈដោយសមធម៌និងពេញចិត្តដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ ឱ្យសមស្របនឹងសេចក្ដីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀត តាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់។

៤.មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមក្នុងការងារសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។



# សិទ្ធិសម្រាក និងលំហែកំសាន្ត

មនុស្សគ្រប់រូប មានសិទ្ធិឈប់សម្រាក និងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផល និងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់។

២៤
មាត្រា

## ២៥ មាត្រា



# សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់

១.មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាពនិង សុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គម កិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគាំពារ នៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្ដាលមកពី កាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន។

២.មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយ និងការថែទាំពិសេស។ កុមារគ្រប់រូប ទោះកើតពីឪពុកម្ដាយមានខាន់ស្លា ឬឥតខាន់ស្លាក្ដី ត្រូវបានទទួលការពារខាងសង្គមកិច្ចដូចគ្នា។



# សិទ្ធិទទួលបានការអប់រំ

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ។ ការអប់រំត្រូវឥតបង់ថ្លៃ យ៉ាងហោចណាស់ សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច។ ការអប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ។ ការអប់រំឧត្តមសិក្សាត្រូវបើកឱ្យចូលរៀនស្មើភាពគ្នាដោយឈរលើមូលដ្ឋានសមត្ថភាព។

២. ការអប់រំត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ ការអប់រំនេះ ត្រូវលើកកម្ពស់ការយល់ដឹង ការអត់ឱនអធ្យាស្រ័យគ្នា និងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព។

៣. មាតាបិតាមានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន។

២៦

មាត្រា



# សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌ សិល្បៈ និងវិទ្យាសាស្ត្រ

១.មនុស្សគ្រប់រូប មានសិទ្ធិចូលរួមដោយសេរី ក្នុងជីវភាពវប្បធម៌របស់សហគមន៍រីករាយនឹងសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាពវិទ្យាសាស្ត្រ និងបានទទួលផលប្រយោជន៍ពីលទ្ធផលនៃវឌ្ឍនភាពនេះ។

២.មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផលប្រយោជន៍ខាងសីលធម៌ និងសម្ភារដែលបានមកពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈ ដែលជាស្នាដៃរបស់ខ្លួន។

**២៧**

**មាត្រា**



# សិទ្ធិទទួលបានពិភពលោកមួយសេរី និងយុត្តិធម៌

១.មនុស្សគ្រប់រូប មានសិទ្ធិចូលរួមរៀបចំសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិ ដើម្បីឲ្យសិទ្ធិ សេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសនេះ អាចត្រូវបានសម្រេចបានយ៉ាងពេញលេញ។

**២៨**

**មាត្រា**



# ភារកិច្ចចំពោះសហគមន៍របស់អ្នក

១.មនុស្សគ្រប់រូបមានករណីយកិច្ចចំពោះសហគមន៍ ជាកន្លែងតែមួយគត់ដែលអាចបង្កើតបានការរីកចម្រើនដោយសេរី និងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។

២.មនុស្សគ្រប់រូប អាចប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួនបានក្នុងដែនច្បាប់បានកំណត់តែប៉ុណ្ណោះ ក្នុងគោលបំណងធានាការទទួលស្គាល់ និងការគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងដើម្បីបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ។

៣.ទោះជាក្នុងករណីណាក៏ដោយ សិទ្ធិនិងសេរីភាពទាំងនេះ មិនអាចត្រូវបានប្រើប្រាស់ផ្ទុយនឹងគោលការណ៍របស់អង្គការសហប្រជាជាតិឡើយ។

**២៩**

**មាត្រា**



# សិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬ ដកហូតបាន

គ្មានបទបញ្ញត្តិណាមួយនៃសេចក្ដីប្រកាសនេះ អាចត្រូវបានបកស្រាយ ដែលបណ្ដាលឱ្យរដ្ឋ ក្រុម ឬបុគ្គលណាមួយ មានសិទ្ធិបែបណាមួយ ដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយ សំដៅបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្ដីប្រកាសនេះឡើយ។

៣០

មាត្រា